00353731

E40/2/1

**Declassified to Public**
**06 September 2012**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 22 / JUL / 2009
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងព្រហ្មទណ្ឌលេខ៖ | ០០១/១៨-០៧-២០០៧-អវតក/អជសដ |
| ដាក់ជូន ៖ | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់៖ | ២២/០៧/០៩ |
| ភាគីអ្នកដាក់ ៖ | សហមេធាវីការពារក្ដីលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច |
| ភាសាដើម៖ | បារាំង |
| ប្រភេទឯកសារ៖ | សម្ងាត់បំផុត |

---

# សេចក្ដីបញ្ជាក់លើសំណើសុំឲ្យកោះអញ្ជើញលោកស្រី មាស គីមសឿន (D14) មកកាន់អង្គសវនាការ

---

**អ្នកដាក់ឯកសារ:**

**សហមេធាវីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច**

មេធាវី ការ សាវុត្ថ

មេធាវី François ROUX

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន ជាប្រធាន

លោកស្រីចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មណី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / JUL / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. តាមរយៈលិខិតជាលាយលក្ខណ៍អក្សររបស់ខ្លួនផ្ញើជូនមេធាវីការពារក្តី ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យមេធាវីការពារក្តី បង្ហាញពីជំហររបស់ខ្លួនចំពោះសំណើសុំដែលខ្លួនបានដាក់ទៅអង្គជំនុំជម្រះ ដើម្បីស្នើឱ្យមានការកោះអញ្ជើញលោកស្រី មាស គឹមសឿវ មកកាន់អង្គសវនាការ ដោយយោងទៅលើសេចក្តីសន្និដ្ឋាននានាដែលធ្វើឡើងដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។[1]

២. បន្ទាប់ពីបានឃើញសេចក្តីសន្និដ្ឋានអស់ទាំងនេះ និងបន្ទាប់ពីបានទទួលនូវសេចក្តីអត្ថាធិប្បាយពីសំណាក់លោកស្រី មាស គឹមសឿវ រួចមក មេធាវីការពារក្តីសូមធ្វើកំណត់សម្គាល់ដូចខាងក្រោមៈ

៣. មេធាវីការពារក្តីយល់ឃើញថា ការអនុញ្ញាតិឱ្យមានការចូលខ្លួននេះវាជារឿងចាំបាច់ ដោយហេតុថាៈ

- មូលហេតុទីមួយៈ លោកស្រី មាស គឹមសឿវ បានបញ្ជាក់ប្រាប់មេធាវីការពារក្តីអំពីចេតនារបស់លោកស្រី ក្នុងការចូលខ្លួនមកបំភ្លឺនៅចំពោះមុខអង្គសវនាការនៃអង្គជំនុំជម្រះសាលាដំបូង លើកលែងតែស្ថានភាពសុខភាពរបស់លោកស្រីមិនអំណោយផលនៅក្នុងអំឡុងពេលសវនាការប៉ុណ្ណោះ។

- មូលហេតុទីពីរៈ ក្នុងនាមជាម្តាយរបស់ជនជាប់ចោទ លោកស្រី មាស គឹមសឿវ មិនមានកាតព្វកិច្ចចាំបាច់ក្នុងការធ្វើសម្បថនោះទេ ពីព្រោះថាលោកស្រីត្រូវបានលើកលែងពីកាតព្វកិច្ចនេះ ដោយផ្អែកតាមវិធាន ២៤ (២) (ក) នៃវិធានផ្ទៃក្នុង ហើយថេរៈវេលាសរុបនៃការផ្តល់ចម្លើយនោះ មិនត្រូវមានរយៈពេលលើសពី ១០ នាទី ឡើយ ក្នុងករណីដែលមិនមានការសួរដេញដោលណាមួយត្រូវបានស្នើឡើងដោយគូភាគីទេនោះ។

---

[1] ឯកសារលេខ E40/2 និង E105

- មូលហេតុទីបីៈ ផ្អែកលើមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ មេធាវីការពារក្តីយល់ឃើញថាការចូលខ្លួននេះមានលក្ខណៈចាំបាច់ សម្រាប់កិច្ចពិភាក្សាដេញដោលលើស្ថានសម្រាលទោសនាពេលខាងមុខ។

៤. ម្យ៉ាងទៀត មេធាវីការពារសូមឯកភាពលើសេចក្តីសន្និដ្ឋាន ដែលធ្វើឡើងដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ហើយដែលតាមរយៈសេចក្តីសន្និដ្ឋាននោះ អាស័យដ្ឋានរបស់លោកស្រី មាស គឹមសៀវ ត្រូវទុកជាការសម្ងាត់។ ផ្ទុយទៅវិញ មេធាវីការពារយល់ឃើញថាវាមិនមានភាពចាំបាច់ទេក្នុងការចាត់ឲ្យមានការបំផ្លែងសម្លេងរបស់លោកស្រី មាស គឹមសៀវ នោះ ដោយហេតុថាលោកស្រីបានបញ្ជាក់រួចមកហើយថាលោកស្រីមានបំណងផ្តល់សក្ខីកម្មជាសាធារណៈ។

## ហេតុដូច្នេះ

៥. យោងលើមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មេធាវីការពារសូមរក្សាជំហររបស់ខ្លួនក្នុងការស្នើសុំឲ្យមានការកោះអញ្ជើញខ្លួនលោកស្រី មាស គឹមសៀវ មកកាន់អង្គសវនាការក្នុងឋានៈជាម្តាយរបស់ជនជាប់ចោទ។

## សុំរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | |
|---|---|---|
| សហមេធាវីទាំងពីរ<br>មេធាវី **ការ សាវុត្ថ**<br>មេធាវី **François ROUX** | ភ្នំពេញ | [signatures] |
| ឈ្មោះ | ទីកន្លែង | ហត្ថលេខា |